ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ០៣៧៥ ព.ណ.វិ.ព.ក.ស

ថ្ងៃព្រហស្បតិ៍ ៧កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១

# សេចក្តីជូនដំណឹង

## ស្តីពីអាហារូបករណ៍ ក្រោមកម្មវិធី "KOREA INTERNATIONAL COOPERATION AGENCY" សម្រាប់ឆ្នាំសិក្សា ២០២១-២០២២

**យោង:** - លិខិតរបស់ KOREA INTERNATIONAL COOPERATION AGENCY ប្រចាំព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១។

- ចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រី ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១។

វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ សូមគោរពជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីរាជការក្រោមឱវាទក្រសួងពាណិជ្ជកម្ម** មេត្តាជ្រាបថា៖ ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េបានផ្តល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជូនដល់មន្ត្រីរាជការ នៃក្រសួងពាណិជ្ជកម្មសម្រាប់ឆ្នាំសិក្សា ២០២១-២០២២។

កម្មវិធីអាហារូបករណ៍នេះ ចាប់ផ្តើមទទួលពាក្យចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០២១។ ចំពោះបេក្ខជនដែលមានចំណាប់អារម្មណ៍លើ កម្មវិធីអាហារូបករណ៍ខាងលើអាចដាក់ពាក្យស្នើសុំអាហារូបករណ៍តាមរយៈគេហទំព័រ http://www.koica.go.kr/khm_en/8141/subview.do។ដើម្បីទទួលបានព័ត៌មានលម្អិតសូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទ: ០២៣ ៩៦៤ ១៥០ ឬសារអេឡិចត្រូនិច koicascholar@gmail.com ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីរាជការក្រោមឱវាទក្រសួងពាណិជ្ជកម្ម** មេត្តាជ្រាបជាព័ត៌មាន។

សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម